THE SCHOOL DISTRICT OF PHILADELPHIA

ការិយាល័យអគ្គនាយកក្រសួងអប់រំ
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
អគ្គនាយកក្រសួងអប់រំ

ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០២៣

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ដោយសារតែគ្រូបង្រៀន និងកម្មវិធីសិក្សាដែលមានគុណភាពខ្ពស់មានសារៈសំខាន់សម្រាប់បង្កើនជោគជ័យរបស់សិស្ស **ក្រសួងអប់រំបានសន្យាផ្តល់ប្រាក់ចំនួន ៧០ លាន ដុល្លារ ដើម្បីទិញ និងប្រើធនធានសម្រាប់ការបង្ហាត់បង្រៀនថ្មីៗ សម្រាប់ការអាន គណិតវិទ្យា និងវិទ្យាសាស្ត្រ។ នេះគឺជាការវិនិយោគមិនដែលមានក្នុងប្រវត្តិសាស្ត្រទៅលើក្មេងរបស់ទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដែលស្របតាម ផែនការយុទ្ធសាស្ត្រថ្មី (new strategic plan) របស់ក្រសួងអប់រំ – *Accelerate Philly*។** ផែនការយុទ្ធសាស្ត្រគឺជាផែនការកម្រិតខ្ពស់របស់ក្រសួងអប់រំសម្រាប់បម្រើសិស្ស គ្រូបង្រៀន ក្រុមគ្រួសារ និងសហគមន៍ ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ហើយតំណាងឱ្យសកម្មភាពដែលយើងនឹងធ្វើដើម្បីពន្លឿនជោគជ័យក្នុងការសិក្សារបស់សិស្ស។

ដើម្បីធ្វើយ៉ាងណាឱ្យមានការផ្លាស់ប្តូរដោយរលូន ក្រសួងអប់រំនឹងចាត់វិធានការតាមដំណាក់កាល ដើម្បីប្រើធនធានសម្រាប់ការបង្ហាត់បង្រៀនថ្មីលើមុខវិជ្ជាផ្សេងៗ។ បន្ទាប់ពីការវាយតម្លៃយ៉ាងយកចិត្តទុកដាក់លើតម្រូវការរបស់សិស្ស នៅក្នុងដំណាក់កាលទីមួយ យើងនឹងប្រើធនធានគណិតវិទ្យាថ្មីសម្រាប់ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២ សម្រាប់ឆ្នាំសិក្សា ២០២៣-២៤។ ខ្ញុំពិតជារំភើបចិត្តក្នុងការប្រកាសថា យើងបានជ្រើសរើស Imagine Learning LLC/Illustrative Mathematics ជាឈ្មួញដែលនឹងផ្តល់នូវធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗថ្មី ស្របតាមស្តង់ដារ និងមានគុណភាពខ្ពស់របស់យើង សម្រាប់គណិតវិទ្យា។ ខ្ញុំសុំឱ្យលោកអ្នកចូលមើលគេហទំព័ររបស់ឈ្មួញពួកគេ ដើម្បីស្វែងយល់បន្ថែម និងស្វែងរកព័ត៌មានដែលមានអំពីសម្ភារៈ។

បន្ទាប់ពីបានប្រើធនធានគណិតវិទ្យាសម្រាប់ថ្នាក់មត្តេយ្យ ដល់ទី ១២ យើងមានគម្រោងចាប់ផ្តើមធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗផ្នែកគណិតវិទ្យាថ្នាក់មុនមត្តេយ្យ និងអង់គ្លេស (ELA) ថ្នាក់មុនមត្តេយ្យ ដល់ថ្នាក់ទី ១២ ដែលចាប់ផ្តើមនៅឆ្នាំសិក្សា ២០២៤-២០២៥។ ធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗសម្រាប់ ការអភិវឌ្ឍន៍ភាសាអង់គ្លេស (ELD) ថ្នាក់ទី ៣ ដល់ទី ១២ វិទ្យាសាស្ត្រ ថ្នាក់មុនមត្តេយ្យ ដល់ទី ១២ និងការអប់រំពិសេស ថ្នាក់មត្តេយ្យ ដល់ទី ១២ (ជាធនធានបន្ថែម) នឹងយកមកប្រើក្នុងដំណាក់កាលក្រោយៗនាពេលអនាគត។

ធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗ រួមមាន សៀវភៅសិក្សា សកម្មភាពតាមបណ្តាញអ៊ិនធ័រណិត មេរៀន និងសម្ភារៈឌីជីថល គឺជាឧបករណ៍ដែលអ្នកអប់រំប្រើដើម្បីផ្តល់កម្មវិធីសិក្សា និងអភិវឌ្ឍចំណេះដឹងរបស់

សិស្ស។ រួមគ្នា ធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗ  និងកម្មវិធីសិក្សាដែលឆ្លើយតបនឹងវប្បធម៌មានសារៈសំខាន់ក្នុងការពន្លឿនជោគជ័យរបស់សិស្ស និងជំរុញការអង់អាចដល់សិស្សឱ្យទទួលបានជោគជ័យនាពេលអនាគត។

ចាប់ផ្តើមនៅរដូវក្តៅនេះ និងក្នុងអំឡុងឆ្នាំសិក្សា នឹងមានឱកាសជាបន្តបន្ទាប់សម្រាប់អ្នកអប់រំ ក្រុមគ្រួសារ និងសិស្សានុសិស្ស ដើម្បីស្វែងយល់ឱ្យដឹងពីធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗថ្មី និងបទពិសោធន៍ពីរបៀបដែលធនធានទាំងនោះដំណើរការក្នុងការប្រើផ្ទាល់។ នឹងមានវគ្គផ្តល់ព័ត៌មានតាមបណ្តាញអ៊ិនធឺណិត និងតាមការជួបផ្ទាល់ ដែលលោកអ្នកអាចធ្វើអន្តរកម្មជាមួយអ្នកផ្តល់ធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗ និងរៀនពីរបៀបគាំទ្រដល់ការរៀនសូត្ររបស់កូនលោកអ្នកនៅផ្ទះ។ លោកអ្នកអាចរំពឹងថានឹងមានទំនាក់ទំនងជាទៀងទាត់អំពីវគ្គទាំងនេះនាពេលអនាគតដ៏ខ្លីខាងមុខនេះ។

ខ្ញុំបាននិយាយតាំងពីមុនមកទល់ពេលនេះថា – យើងជាដៃគូរបស់លោកអ្នកក្នុងការអប់រំកូនលោកអ្នក។ ដំណើរការជ្រើសរើសធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗគឺជាឧទាហរណ៍ដ៏ភ្លឺថ្លានៃភាពជាដៃគូនេះ។ តាំងពីខែមករាមក លោកអ្នកគឺជាដៃគូរបស់យើងក្នុងដំណើរការជ្រើសរើសធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗនេះ។ លោកអ្នកបានចូលរួមជាមួយឈ្មួញនានានៅពេលមានកម្មវិធី ជួបគ្នា និង រាក់ទាក់ជាមួយឈ្មួញ ហើយបានផ្តល់មតិកែលម្អដ៏សំខាន់ តាមរយៈនៃការស្ទង់មតិ វគ្គចូលរួមផ្ទាល់ និងការបង្ហាញមេរៀន។ **សម្រាប់អ្វីៗទាំងអស់នេះ យើងសូមអរគុណ**!

នៅពេលដែលយើងបន្តធ្វើការរួមគ្នា ខ្ញុំជឿថាយើងអាចបង្កើន *Accelerate Philly* សម្រេចបាននូវ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និង ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ របស់ក្រុមប្រឹក្សាភិបាលអប់រំ (Board of Education’s Goals & Guardrails) ហើយរៀបចំសិស្សទាំងអស់ឱ្យស្រមៃ និងសម្រេចបាននូវអនាគតដែលពួកគេចង់បាន។

ក្នុងភាពជាដៃគូ

Tony

Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា